| | |
|---|---|
| **TẬP ĐOÀN CÔNG NGHIỆP CAO SU VIỆT NAM** | **CỘNG HÒA XÃ HỘI CHỦ NGHĨA VIỆT NAM**<br>**Độc lập - Tự do - Hạnh phúc** |
| Số: 2919 /CSVN-QLKT | *TP. Hồ Chí Minh, ngày 23 tháng 9 năm 2024* |

**HỘI THI BÀN TAY VÀNG**
**THU HOẠCH MỦ CAO SU NĂM 2024**

V/v ban hành bộ đề thi lý thuyết tiếng Campuchia.

Kính gửi : Các đơn vị tham gia Hội thi Bàn tay vàng Thu hoạch mủ cao su Năm 2024 tại Campuchia

Tập đoàn Công nghiệp Cao su Việt Nam (Tập đoàn) đã ban hành bộ đề thi Lý thuyết trong văn bản số 2328/CSVN-QLKT ngày 01/8/2024, gồm 80 câu hỏi về quản lý, chăm sóc và thu hoạch trên vườn cây cao su kinh doanh;

Tiếp theo đó, Ban Tổ chức Hội thi cũng đã có văn bản 2726/CSVN-QLKT ngày 05/9/2024 gửi Văn phòng đại diện VRG tại Campuchia rà soát nội dung biên dịch bộ đề lý thuyết sang tiếng Campuchia;

Qua công văn này, Tập đoàn ban hành chính thức bộ đề lý thuyết sử dụng trong Hội thi Bàn tay vàng thu hoạch mủ cao su năm 2024 dành cho thí sinh tham gia sử dụng ngôn ngữ Campuchia (đính kèm).

*Lưu ý:*

(1) Ngoài phần chọn ngẫu nhiên trong bộ đề 2024 để đưa vào đề thi lý thuyết của Hội thi, Ban Giám khảo sẽ có thêm 1-2 câu hỏi mở (cũng ở dạng trắc nghiệm) cập nhật kiến thức sản xuất có liên quan đến lĩnh vực thu hoạch mủ;

(2) Đơn vị tự ôn luyện cho công nhân các quy ước ký hiệu lỗi vi phạm kỹ thuật cạo được quy định trong Quy trình Kỹ thuật dưới đây:

| | | | |
|---|---|---|---|
| - Sát | ‖ | - Miệng cạo gợn sóng | W |
| - Phạm nhẹ | Λ | - Miệng cạo lệch | ≥ |
| - Phạm nặng | Ⱥ | - Không vuông góc | L |
| - Cạn nhẹ | V | - Vệ sinh kém | △ |
| - Cạn nặng | ∀ | - Cây bỏ cạo | ⋈ |
| - Mỏng dăm | ⊖ | - Tận thu kém | ▽ |
| - Dày dăm nhẹ | — | - Trang bị, chăm sóc cây cạo kém | ⌖ |
| - Dày dăm nặng | —×— | - Vi phạm cường độ cạo | ᚼ |

Đề nghị đơn vị tham gia Hội thi Bàn tay vàng có thí sinh người Campuchia triển khai thông báo đến công nhân để chuẩn bị kiến thức lý thuyết tham gia Hội thi.

Trân trọng./.

**KT. TỔNG GIÁM ĐỐC**
**PHÓ TỔNG GIÁM ĐỐC**

**Phạm Hải Dương**
**TRƯỞNG BAN TỔ CHỨC HỘI THI**

***Nơi nhận :***
- Như trên;
- Chủ tịch HĐQT TĐ 'để b/c';
- TGĐ TĐ 'để b/c';
- BTC Hội thi 'để biết';
- Lưu: VT, QLKT.

**សាធារណរដ្ឋសង្គមនិយមវៀតណាម**
**ឯករាជ្យ សេរីភាព សុភមង្គល**

**សម្ព័ន្ធឧស្សាហកម្មកៅស៊ូវៀតណាម**

TẬP ĐOÀN CÔNG NGHIỆP CAO SU VIỆT NAM
CÔNG TY CỔ PHẦN
M.S.D.N: 0301266564
QUẬN 3 - T.P. HỒ CHÍ MINH

**កម្រងវិញ្ញាសារប្រឡងផ្នែកទ្រឹស្ដីសម្រាប់ឆ្នាំ 2024 (80 សំណួរ)**

*(ភ្ជាប់តាមលិខិតលេខ ២១១១ /CSVN-QLKT ចុះថ្ងៃទី ២១ / ១ / ២០២៤ )*

**សំណួរទី1 ៖ ចូររៀបរាប់អំពីស្តង់ដារនៃចំការកៅស៊ូត្រូវបានដាក់ឲ្យចៀរជ័រ៖**

a. ស្តង់ដារដើមកៅស៊ូអាចបើកមុខចៀរជ័របាន គឺ ទំហំតួដើមចាប់ពី 50cm ឡើងទៅ និងសំបកត្រូវមានកំរាស់ចាប់ពី 6mm ឡើងទៅ វាស់នៅកំពស់ 1m ឃ្លាតពីដី

b. ឡូត៍កៅស៊ូមិនទាន់ឲ្យផលដែលមានអត្រាពី 50% ឡើងទៅ ជាដើមកៅស៊ូចូលស្តង់ដារបើកមុខចៀរនោះ គឺត្រូវបានដាក់ឲ្យចៀរជ័រ

c. ចំពោះចំការដែលមានអត្រាលើសពី 90% ជាដើមកៅស៊ូចូលស្តង់ដារបើកមុខចៀរ គឺ អាចបើកមុខចៀរលើដើមទាំងអស់នៅសល់ក្នុងចំការ ដែលមានទំហំតួដើមចាប់ពី 40cm ឡើងទៅ

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី2 ៖ តើសញ្ញាសន្មតផ្ទាំងចៀរ HO-4 មានន័យដូចម្តេច?**

a. តួអក្សរ H ជាសញ្ញាសន្មត ផ្ទាំងចៀរខ្ពស់ (ចៀរផ្កាប់)

b. តួអក្សរ O ជាសញ្ញាសន្មត សំបកកំណើត

c. លេខ 4 គឺជាផ្ទាំងចៀរទី4 ដែលបានបែងចែក

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី3 ៖ តើសញ្ញាសន្មតផ្ទាំងចៀរ BO-2 មានន័យដូចម្តេច?**

a. <u>ចៀរលើផ្ទាំងចៀរទាប (ចៀរផ្ងារ) សំបកកំណើត ផ្ទាំងចៀរទី2</u>

b. ចៀរលើផ្ទាំងចៀរខ្ពស់ សំបកកំណើត ផ្ទាំងចៀរទី2

c. ចៀរលើផ្ទាំងចៀរទាប (ចៀរផ្ងារ) សំបកកំណើត ផ្ទាំចៀរទី2

d. ចៀរលើផ្ទាំងចៀរខ្ពស់ សំបកដុះថ្មីឡើងវិញ ផ្ទាំងចៀរទី2

**សំណួរទី4 ៖ តើក្នុងសំបកដើមកៅស៊ូ បំពង់ជ័រមានច្រើនបំផុតនៅត្រង់ណា?**

a. ស្រទាប់ខាងក្រៅ

b. ស្រទាប់កណ្តាល

c. <u>ស្រទាប់ខាងក្នុង (សំបកទន់)</u>

d. ឈើខ្ចី (កំប៊ីយូម)

**សំណួរទី5 ៖ តើកត្តាទាំងឡាយណាខាងក្រោមនេះ អាចប៉ះពាល់ដល់លំហូរទឹកជ័រលើចង្អូរមុខចៀររបស់ដើមកៅស៊ូ?**

a. លំអៀងសម្ពាធ ការសាយភាយចំហាយទឹក កត្តាខ្យល់ និង កម្រិតសំណើមបរិយាកាស

b. កំហាប់ជ័រកៅស៊ូក្នុងទឹកជ័រ និង លទ្ធភាពទាញយកជ័រ

c. កត្តាពូជ បច្ចេកទេសចៀរជ័រ និង ការប្រើប្រាស់ថ្នាំរំញោច

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី6 ៖ តើរបបចៀរមានន័យដូចម្តេច?**

a. គឺជាចំនួនថ្ងៃធ្វើការចៀរជ័រជាក់ស្តែងក្នុងឆ្នាំ

b. ជាមូលដ្ឋានដើម្បីគណនាការចំណាយថ្លៃឈ្នួលចៀរជ័រសម្រាប់កម្មករចៀរជ័រ

c. <u>ជាការកំណត់ដោយរួមផ្សំរវាងប្រវែងមុខចៀរ សង្វាក់ចៀរ និងការប្រើប្រាស់ថ្នាំរំញោច</u>

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី7 ៖ តើហេតុអ្វីមិនអនុញ្ញាតឲ្យភ្ជួរដីតាមចន្លោះជួរកៅស៊ូ (ចន្លោះ 6m) ក្នុងចំការអាជីវកម្ម?**

a. ភ្ជួរដីតាមចន្លោះជួរកៅស៊ូគ្មានផលចំណេញផ្នែកសេដ្ឋកិច្ច

b. ភ្ជួរដីតាមចន្លោះជួរកៅស៊ូអាចបង្កបួសដល់ប្រព័ន្ធឫសស្រូបយកសារជាតុចិញ្ចឹមរបស់ដើមកៅស៊ូ និង បង្កើនអត្រាស្ងួតមុខចៀរ

c. ភ្ជួរដីតាមចន្លោះជួរកៅស៊ូ នឹងរាំងស្ទះដល់លទ្ធភាពផ្តល់ជ័ររបស់ដើមកៅស៊ូ

d. <u>ពីព្រោះភ្ជួរដីតាមចន្លោះជួរកៅស៊ូ នឹងធ្វើអោយដាច់ឫសស្រូបយកសារជាតុចិញ្ចឹមរបស់ដើមកៅស៊ូ និងបង្កអោយហូរច្រោះដី</u>

**សំណួរទី8 ៖ តើការសំអាតស្មៅតាមចន្លោះជួរដើម សំរាប់ចំការកៅស៊ូអាជីវកម្ម ត្រូវអនុវត្តដូចម្តេច?**

a. អនុវត្តវិធានការភ្ជួរត្រឡប់ដី ដើម្បីសម្លាប់អស់ស្មៅចង្រៃ

b. គួបផ្សំរវាងហត្ថកម្មជាមួយនឹងគ្រឿងយន្ត ដើម្បីគ្រប់គ្រងស្មៅចង្រៃឲ្យមានប្រសិទ្ធិភាព

c. ធ្វើការកាត់ស្មៅក្នុងរដូវភ្លៀង ដោយហត្ថកម្ម ចំនួនម្តង/ឆ្នាំ តែប៉ុណ្ណោះ

d. <u>ធ្វើការកាត់ស្មៅតាមចន្លោះជួរ ដោយរក្សាទុកគម្របស្មៅមានកំពស់ពី 10 ទៅ 15cm ដើម្បីទប់ស្កាត់ការហូរច្រោះ</u>

**សំណួរទី9 ៖ តើការសំអាតស្មៅតាមជួរដើម សំរាប់ចំការកៅស៊ូអាជីវកម្ម ត្រូវអនុវត្តដូចម្តេច?**

a. ចំពោះដីរាបស្មើ សំអាតឲ្យអស់ស្មៅនៅសងខាងជួរដើម ក្នុងចំងាយពីគល់ចេញទៅម្ខាងចំនួន 1m

b. ចំពោះដីជម្រាល គ្រាន់តែសំអាតស្មៅក្នុងរង្វង់ ចំងាយពីគល់ចេញទៅជុំវិញចំនួន 1m

c. ចំណែកផ្ទៃដីដែលនៅសល់ ធ្វើការកាត់សំអាតដោយរក្សាទុកគម្របស្មៅមានកំពស់ពី 10 ទៅ 15cm

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី10 ៖ តើមូលហេតុអ្វីត្រូវផ្លាស់ប្តូរទិសចាប់ផ្តើមធ្វើការចៀរ ក្រោយវេនចៀរនីមួយៗ?**

a. ដើម្បីទុកពេលឲ្យដើមកៅស៊ូក្នុងរានចៀរមានរយៈពេលហូរជ័រប្រហែលគ្នា និង ទិន្នផលជ័រប្រមូលបានច្រើន

b. សម្រួលដល់កម្មករអាចគ្រប់គ្រងរានចៀររបស់ខ្លួនកាន់តែម៉ត់ចត់ និង ងាយស្រួលក្នុងការត្រួតពិនិត្យ ចំពោះបញ្ហាលួចយកជ័រកៅស៊ូ

c. ចៀសវាងកុំអោយដើមកៅស៊ូស្ងួតមុខចៀរ ត្រួតពិនិត្យ និងបង្កាជម្ងឺក្នុងចំការ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី11 ៖ តើដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងកម្មករចៀរជ័រ និង បង្កើនផលិតភាពរបស់កម្មករ អាចជ្រើសយកដំណោះស្រាយមួយណាខាងក្រោមនេះ?**

a. បន្ថយសង្វាក់ចៀរ d4 ដោយមានចំនួនដងនៃការប្រើថ្នាំរំញោចសមស្រប គួបផ្សំនឹងការប្រើប្រាស់របាំងការពារផ្ទាំងចៀរ និង គម្របការពារចានត្រងជ័រ

b. អនុវត្តវិធានការប្រមូលជ័រកកតាមលក្ខណៈធម្មជាតិ បង្កើនចំនួនដើមចៀរសម្រាប់រានចៀរ (750 ដើម) មិនចាំបាច់សាជ័រជារៀងរាល់ថ្ងៃ ប្រើប្រាស់ចានត្រងជ័រធំ គួបផ្សំជាមួយវិធានការដាក់របាំងការពារទឹកភ្លៀង។

c. ធ្វើការចៀរជ័រតាមសង្វាក់ចៀរ d3 បង្កើនចំនួនដងធ្វើរំញោច បន្ថយចំនួនដើមចៀរសម្រាប់រានចៀរ និង ធ្វើការសាជ័រឲ្យបានច្រើនដង

d. មានតែចំឡើយ a និងចំឡើយ b គឺត្រូវ

**សំណួរទី12 ៖ តើសំបកចៀរត្រូវបានបង្កើតឡើងវិញអាស្រ័យទៅលើកត្តាអ្វីខ្លះ?**

a. លក្ខខ័ណ្ឌនៃទីវាលខាងក្រៅ (អាកាសធាតុ លក្ខណៈដី ...) ដង់ស៊ីតេដាំ និងស្ថានភាពជម្ងឺបំផ្លាញ

b. លក្ខណៈពិសេសរបស់ពូជ និង លក្ខខ័ណ្ឌនៃការដាក់ជីថែទាំចំការ

c. របបចៀរ និង បច្ចេកទេសចៀរជ័រដែលបានអនុវត្តនៅតាមចំការ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី១៣ ៖ ប្រសិនបើផ្ទាំងចៀរសើមដោយសារការលេចធ្លាយរបាំង/គម្របការពារទឹកភ្លៀង តើកម្មករចៀរជ័រត្រូវតែមានដំណោះស្រាយដូចម្តេច?**

a. នៅតែរក្សាការចៀរជ័រលើដើមកៅស៊ូនោះ ដោយមិនចាំបាច់ធ្វើការដោះស្រាយ ឬ ជួសជុលអ្វីទេ

b. ត្រូវបញ្ឈប់ចៀរជ័រលើដើមកៅស៊ូនោះ គូសចំណាំកន្លែងលេចធ្លាយដើម្បីជួសជុល រាយការណ៍ទៅប្រធានក្រុម និងរៀបចំធ្វើការជួសជុលភ្លាមនៅពេលដែលអាកាសធាតុអំណោយផល ដើម្បីបំពេញគ្រប់លក្ខខ័ណ្ឌសម្រាប់ការចៀរជ័របន្តបន្ទាប់

c. នៅតែធ្វើការចៀរជ័រលើដើមកៅស៊ូនោះ និង គូសចំណាំកន្លែងលេចធ្លាយដើម្បីដោះស្រាយ ឬ ជួសជុលនៅពេលដែលអាកាសធាតុអំណោយផល

d. បញ្ឈប់ចៀរជ័រលើដើមកៅស៊ូនោះ និងធ្វើការចៀរជ័រឡើងវិញនៅពេលដែលផ្ទាំងចៀរស្ងួត ដោយមិនចាំបាច់ធ្វើការដោះស្រាយ ឬ ជួសជុលអ្វីទេ

**សំណួរទី14 ៖ តើហេតុអ្វីមុខចៀរត្រូវរៀបចំឲ្យត្រូវតាមកំរិតចំណោតចុះក្រោម ពីខាងឆ្វេងទៅស្តាំ ដោយប្រៀបធៀបនឹងអ័ក្សផ្តេក?**

a. ពីព្រោះអាចកាត់បានប្រព័ន្ធសរសៃជ័រច្រើនបំផុត

b. ពីព្រោះជាតម្រូវការនៃកាយវិការចៀរជ័រ

c. ពីព្រោះតាមទម្លាប់ដែលមានតាំងពីយូរមកហើយ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី15 ៖ តើហេតុអ្វីពេលគូសបែងចែកមុខចៀរ ដោយគួបផ្សំទាំងមុខចៀរផ្ការផង និងផ្កាប់ផងលើផ្ទាំងចៀរដែលមានទិសដូចគ្នា ត្រូវអោយមានគំលាតពីមុខចៀរមួយទៅមុខចៀរមួយទៀតតិចបំផុត 30cm?**

a. ដើម្បីចៀសវាងការត្រួតគ្នាលើតំបន់ទាញយកជ័រ

b. ដើម្បីងាយស្រួលត្រួតពិនិត្យបច្ចេកទេសចៀរលើមុខចៀរនីមួយៗ

c. ដើម្បីកាត់បន្ថយការឆ្លងជម្ងឺលើផ្ទាំងចៀរ

d. ដើម្បីសន្សំសំចៃសម្ភារៈបំពាក់សំរាប់ដើមកៅស៊ូ

**សំណួរទី16 ៖ តាមការកំណត់ចំពោះការចៀរផ្កាប់ដោយមានការត្រួតពិនិត្យ តើកំពស់បើកមុខនៅបន្ទាត់ព្រំខាងមុខត្រូវរៀបចំអោយខ្ពស់ពីដីចំនួនប៉ុន្មាន?**

a. ពី 1,1m ដល់ 1,3m

b. ពី 1,3m ដល់ 2m

c. ពី 2m ដល់ 3m

d. ពី 3m ឡើងទៅ

**សំណួរទី17 ៖ តើការកំណត់ចំពោះឧបករណ៍សម្រាប់ការគូសបែងចែកមុខចៀរ ផ្ទាំងចៀរលើដើមកៅស៊ូ រួមមានអ្វីខ្លះ?**

a. ម៉ែត្រឈើបែងចែកមុខចៀរប្រវែង1,5m ដែកឆូត(កង្វា) ខ្សែក្លួចបីចំណុច ឬ ម៉ែត្រសំពត់ ខ្នាតក្រិតស្នាមចំណាយអាចម៍ពន្លាក ឧបករណ៍កំណត់មុំ(ទង់ជ័យ)មុខចៀរផ្ការ$30^0$ ឧបករណ៍កំណត់មុំមុខចៀរផ្កាប់$42^0$

b. ម៉ែត្រឈើបែងចែកមុខចៀរប្រវែង1,5m ដែកឆូត(កង្វា) ខ្សែក្លួចបីចំណុច ឬ ម៉ែត្រសំពត់ ខ្នាតក្រិតស្នាមចំណាយអាចម៍ពន្លាក ឧបករណ៍កំណត់មុំ(ទង់ជ័យ)មុខចៀរផ្ការ$32^0$ ឧបករណ៍កំណត់មុំមុខចៀរផ្កាប់$42^0$

c. ម៉ែត្រឈើបែងចែកមុខចៀរប្រវែង1,5m ដែកឆូត(កង្វា) ខ្សែក្លួចបីចំណុច ឬ ម៉ែត្រសំពត់ ខ្នាតក្រិតស្នាមចំណាយអាចម៍ពន្លាក ឧបករណ៍កំណត់មុំ(ទង់ជ័យ)មុខចៀរផ្ការ$32^0$ ឧបករណ៍កំណត់មុំមុខចៀរផ្កាប់$45^0$

d. ម៉ែត្រឈើបែងចែកមុខចៀរប្រវែង1,5m ដែកឆូត(កង្វា) ខ្សែក្លួចបីចំណុច ឬ ម៉ែត្រសំពត់ ខ្នាតក្រិតស្នាមចំណាយអាចម៍ពន្លាក ឧបករណ៍កំណត់មុំ(ទង់ជ័យ)មុខចៀរផ្ការ$34^0$ ឧបករណ៍កំណត់មុំមុខចៀរផ្កាប់$45^0$

**សំណួរទី18 ៖ តើហេតុអ្វីត្រូវធ្វើការគូសបែងចែកមុខចៀរ ដើម្បីត្រៀមទុកមុនពេលបើកមុខចៀរ នៅដើមរដូវជារៀងរាល់ឆ្នាំ ?**

a. ពីព្រោះអាចកាត់បានសរសៃជ័រច្រើនបំផុត និងរក្សាបាននូវទិន្នផល និងបរិមាណផលិតផលរបស់ចំការ

b. ពីព្រោះជាតម្រូវការនៃកាយវិការចៀរជ័រ ជួយឲ្យកម្មករអាចផ្លាស់ទីបានដោយងាយស្រួល និងបង្កើនផលិតភាពការងារ

c. ដើម្បីរក្សាចំណោតមុខចៀរឲ្យបានត្រឹមត្រូវតាមការកំណត់ និងធានាដល់ផែនការចំណាយសំបកចៀរ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី19 ៖ តើក្នុងចំការអាជីវកម្ម អាចបើកមុខចៀរលើដើមកៅស៊ូមានទំហំគួដើមចាប់ពី 40cm វាស់នៅកំពស់ 1m ឃ្លាតពីដី នៅពេលណា ?**

a. ចំការបើកមុខចៀរថ្មី ដែលមានអត្រាលើសពី 90% ជាដើមកៅស៊ូចូលស្តង់ដារអាចបើកមុខចៀរបាន

b. នៅដើមឆ្នាំទី3 បើកមុខចៀរលើដើមកៅស៊ូទាំងអស់ ដែលមានទំហំគួដើមលើសពី 40cm

c. នៅដើមឆ្នាំទី4 បើកមុខចៀរលើដើមកៅស៊ូទាំងអស់ ដែលមានទំហំគួដើមលើសពី 40cm

d. ចំឡើយ a និង ចំឡើយ b គឺត្រូវ

**សំណួរទី20 ៖ តើសម្ភារៈសំរាប់បំពាក់លើដើមចៀរ រួមមានអ្វីខ្លះ ?**

a. កងទ្រចាន ស្លាបព្រាបង្ហូរជ័រ និង ចានត្រងជ័រ

b. របាំង ឬ គម្របការពារទឹកភ្លៀងសម្រាប់ផ្ទាំងចៀរ និង ចានត្រងជ័រ

c. ស្លាបព្រាបង្ហូរជ័រ (មុខចៀរផ្កាប់) និង ខ្សែនាំជ័រ (ចៀរអស់ពីផលិតភាពហើយកាប់ដើមយកឈើ)

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី21 ៖ តើហេតុអ្វីត្រូវដាក់របាំង ឬ គម្របការពារទឹកភ្លៀងសម្រាប់ផ្ទាំងចៀរ ?**

a. ដើម្បីទប់ស្កាត់ និងកាត់បន្ថយទឹកភ្លៀងហូរពីលើស្លឹកចុះមកក្រោម ធ្វើអោយសើមផ្ទាំងចៀរ

b. ដើម្បីការពារផ្ទាំងចៀរ និង មុខចៀរកុំអោយសើម ដែលអាចចៀរជ័របានជម្មតាក្នុងរដូវភ្លៀង នៅថ្ងៃដែលភ្លៀងធ្លាក់តិច

c. កាត់បន្ថយការបាត់បង់ទិន្នផលជ័រក្នុងរដូវភ្លៀង

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី22 ៖ តើបច្ចេកទេសចៀរបើកមុខ ដោយចៀរចោលចំនួន 3 ពន្លាក៖ ចៀរសើៗតាមគំរូចំណោតមុខចៀរ ចៀរតាមលំនាំឲ្យជ្រៅបន្តិចមានរាងចំណិតត្រសក់ ចៀរឲ្យដល់ជម្រៅតាមបទដ្ឋានបច្ចេកទេស។ ពេលចៀរត្រូវសង្កត់ផ្តិបស្លាបពន្លាកឲ្យជាប់នឹងផ្ទាំងចៀរ ធ្វើការចៀរបន្តិចម្តងៗឲ្យដល់ជម្រៅកំណត់(ស្មើល្មមនឹងផ្លែពន្លាកចៀរ) ជៀសវាងការចៀររបួសនៅកន្លែងបើកមុខ ត្រូវបានអនុវត្តលើចំការណា ?**

a. ចំការទើបបើកមុខចៀរនៅឆ្នាំដំបូង

b. ចំការទើបប្តូរទៅចៀរលើផ្ទាំងចៀរ BO-2 នៅឆ្នាំដំបូង

c. ចំការទើបបើកមុខចៀរលើផ្ទាំងចៀរផ្កាប់ នៅឆ្នាំដំបូង

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី23 ៖ តើកំរិតចំណាយសំបកត្រូវបានអនុញ្ញាតសម្រាប់ការចៀរចោល ដើម្បីបើកមុខចៀរឡើងវិញ (02 ពន្លាក) មានចំនួនប៉ុន្មាន?**

a. តិចបំផុត 0,5cm

b. ពី 0,5 ដល់ 1cm

c. ច្រើនបំផុត 2cm

d. ច្រើនបំផុត 3cm

**សំណួរទី24 ៖ តើហេតុអ្វី ត្រូវធ្វើការចៀរឲ្យដល់ជម្រៅតាមការកំណត់?**

a. ពីព្រោះនឹងរក្សាបានស្រទាប់លីបេ៊ (Libe) វាមានតួនាទីបញ្ជូនសារធាតុអាណាបូលិក (Anabolic) ដែលសំយោគបានពីស្លឹកចុះមកតួដើម ដើម្បីផលិតទឹកជ័រឡើងវិញ

b. ដើម្បីជៀសវាងកុំបង្ករបួសដល់ស្រទាប់ឈើខ្ចី (កំប៊ីយូម) និង រក្សាបានការបញ្ជូនសារធាតុចិញ្ចឹមដើម្បីបង្កើតទឹកជ័រឡើងវិញ និង កុំឲ្យមានស្នាមកំពិកកំពកក្នុងដំណើរការបង្កើតសំបកថ្មីឡើងវិញ

c. ធ្វើការចៀរដល់ជម្រៅកំណត់ នឹងទទួលបាននូវផលចំណេញខ្ពស់បំផុត ដោយសារកាត់បានសរសៃជ័រច្រើនបំផុតនៅស្រទាប់សំបកខាងក្នុង (សំបកទន់) ដែលនៅជិតស្រទាប់ឈើខ្ចីជាងគេ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី25 ៖ តើជម្រៅកំណត់ចំពោះការចៀរជ័រ(ឃ្លាតពីឈើខ្ចី)មានចំនួនប៉ុន្មាន?**

a. ពី 1,0 mm ដល់ 1,3 mm

b. ពី 1,0 mm ដល់ 1,5 mm

c. ពី 1,1 mm ដល់ 1,3 mm

d. ពី 1,1 mm ដល់ 1,5 mm

**សំណួរទី26 ៖ តើហេតុអ្វីការចៀររាក់(ចៀរខ្វះជម្រៅ) ប្រមូលផលជ័រមិនបានច្រើន?**

a. ពីព្រោះមិនប្រមូលបានអស់ទឹកជ័រនៅតំបន់ទាញយកជ័រ

b. ពីព្រោះការចៀររាក់មិនបង្កើតសម្ពាធគ្រប់គ្រាន់ដើម្បីធ្វើអោយទឹកជ័រហូរចេញ

c. ពីព្រោះមិនអាចកាត់បានសរសៃជ័រច្រើន ដែលប្រមូលផ្តុំនៅតំបន់កៀកជិតស្រទាប់ឈើខ្ចី

d. មានតែចំឡើយ a និង ចំឡើយ c គឺត្រូវ

**សំណួរទី27 ៖ ការចៀរប៉ះសាច់ឈើគឺចៀររបួស តើលក្ខណៈស្នាមរបួសដូចម្តេចដែលចាត់ទុកថាចៀររបួសធ្ងន់?**

a. បណ្តោយ ≥ 5 mm ទទឹង > 3 mm

b. បណ្តោយ ≥ 5 mm ទទឹង < 3 mm

c. បណ្តោយ < 5 mm ទទឹង > 3 mm

d. បណ្តោយ < 5 mm ទទឹង < 3 mm

**សំណួរទី28 ៖ តើកំរិតចំណាយអាចម៍ពន្លាក (ចំណាយសំបកចៀរ) ត្រូវបានកំណត់សម្រាប់មុខចៀរផ្កាវ តាមសង្វាក់ចៀរ d3 គឺមានចំនួនប៉ុន្មាន?**

a. ចំណាយអាចម៍ពន្លាក 1,1 mm – 1,3 mm/ពន្លាក និង ចំណាយសំបកចៀរ 18 cm/ឆ្នាំ ជាអតិបរមា
b. ចំណាយអាចម៍ពន្លាក 1,1 mm – 1,5 mm/ពន្លាក និង ចំណាយសំបកចៀរ 18cm/ឆ្នាំ ជាអតិបរមា
c. ចំណាយអាចម៍ពន្លាក 1,2 mm – 1,6 mm/ពន្លាក និង ចំណាយសំបកចៀរ 15cm/ឆ្នាំ ជាអតិបរមា
d. ចំណាយអាចម៍ពន្លាក 1,5 mm – 3 mm/ពន្លាក និង ចំណាយសំបកចៀរ 15cm/ឆ្នាំ ជាអតិបរមា

**សំណួរទី29 ៖ តើកំរិតចំណាយអាចម៍ពន្លាក (ចំណាយសំបកចៀរ) ត្រូវបានកំណត់សម្រាប់មុខចៀរផ្កាវ តាមសង្វាក់ចៀរ d4 គឺមានចំនួនប៉ុន្មាន?**

a. ចំណាយអាចម៍ពន្លាក 1,1 mm – 1,3 mm/ពន្លាក និង ចំណាយសំបកចៀរ 18 cm/ឆ្នាំ ជាអតិបរមា
b. ចំណាយអាចម៍ពន្លាក 1,1 mm – 1,5 mm /ពន្លាក និង ចំណាយសំបកចៀរ 18 cm/ឆ្នាំ ជាអតិបរមា
c. ចំណាយអាចម៍ពន្លាក 1,2 mm – 1,6 mm/ពន្លាក និង ចំណាយសំបកចៀរ 15cm/ឆ្នាំ ជាអតិបរមា
d. ចំណាយអាចម៍ពន្លាក 1,5 mm – 3 mm/ពន្លាក និង ចំណាយសំបកចៀរ 15cm/ឆ្នាំ ជាអតិបរមា

**សំណួរទី30 ៖ តើកំរិតចំណាយអាចម៍ពន្លាក (ចំណាយសំបកចៀរ) ត្រូវបានកំណត់សម្រាប់មុខចៀរផ្កាប់ ដោយមានការត្រួតពិនិត្យ តាមសង្វាក់ចៀរ d3 គឺមានចំនួនប៉ុន្មាន?**

a. ចំណាយអាចម៍ពន្លាកមិនលើសពី 2mm/ពន្លាក និង ចំណាយសំបកចៀរ 2,5cm/ខែ ជាអតិបរមា
b. ចំណាយអាចម៍ពន្លាកមិនលើសពី 2mm/ពន្លាក និង ចំណាយសំបកចៀរ 3cm/ខែ ជាអតិបរមា
c. ចំណាយអាចម៍ពន្លាកមិនលើសពី 2,2mm/ពន្លាក និង ចំណាយសំបកចៀរ 2,5cm/ខែ ជាអតិបរមា
d. ចំណាយអាចម៍ពន្លាកមិនលើសពី 2,2mm/ពន្លាក និង ចំណាយសំបកចៀរ 3cm/ខែ ជាអតិបរមា

**សំណួរទី31 ៖ តើកំរិតចំណាយអាចម៍ពន្លាក (ចំណាយសំបកចៀរ) ត្រូវបានកំណត់សម្រាប់មុខចៀរផ្កាប់ ដោយមានការត្រួតពិនិត្យ តាមសង្វាក់ចៀរ d4 គឺមានចំនួនប៉ុន្មាន?**

a. ចំណាយអាចម៍ពន្លាកមិនលើសពី 2mm/ពន្លាក និង ចំណាយសំបកចៀរ 2,5cm/ខែ ជាអតិបរមា
b. ចំណាយអាចម៍ពន្លាកមិនលើសពី 2mm/ពន្លាក និង ចំណាយសំបកចៀរ 3cm/ខែ ជាអតិបរមា
c. ចំណាយអាចម៍ពន្លាកមិនលើសពី 2,2mm/ពន្លាក និង ចំណាយសំបកចៀរ 2,5cm/ខែ ជាអតិបរមា
d. ចំណាយអាចម៍ពន្លាកមិនលើសពី 2,2mm/ពន្លាក និង ចំណាយសំបកចៀរ 3cm/ខែ ជាអតិបរមា

**សំណួរទី32 ៖ តើហេតុអ្វីមិនអនុញ្ញាតឲ្យចៀរមិនដល់ ឬ ចៀរហួសបន្ទាត់ព្រំខាងមុខ និងបន្ទាត់ព្រំខាងក្រោយលើផ្ទាំងចៀររបស់ដើមកៅស៊ូ?**

a. ចៀរហួសបន្ទាត់ព្រំខាងមុខ និង បន្ទាត់ព្រំខាងក្រោយ នឹងបំផ្លាញដល់ផែនការបែងចែកផ្ទាំងចៀរ
b. ចៀរមិនដល់បន្ទាត់ព្រំខាងមុខ និង បន្ទាត់ព្រំខាងក្រោយ នឹងធ្វើឲ្យប្រវែងមុខចៀរខ្លី សរសៃជ័រកាត់បានតិច និង ទិន្នផលជ័រប្រមូលបានទាប។

c. ចៀរខុសបន្ទាត់ព្រំខាងមុខ និង បន្ទាត់ព្រំខាងក្រោយ នឹងមិនអាចកាត់សរសៃជ័រនៅតំបន់ទាញយកជ័ររបស់ដើមកៅស៊ូបានដល់កំរិតអតិបរមា និង បរិមាណជ័រក្នុងពេលធ្វើការចៀរម្តងៗប្រមូលបានតិច

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី33 ៖ លក្ខណៈអាកាសធាតុមិនអំណោយផលមួយណាខាងក្រោមនេះ ដែលតម្រូវឲ្យផ្អាកធ្វើការចៀរជ័រជាបណ្តោះអាសន្ន**

a. ត្រូវផ្អាកការចៀរជ័រជាបណ្តោះអាសន្ន នៅពេលសីតុណ្ហភាពខ្យល់អាកាសជាមធ្យមចុះទាបជាង 15°C ក្នុងរយៈពេល3ថ្ងៃជាប់គ្នា និងធ្វើការចៀរឡើងវិញនៅពេលសីតុណ្ហភាពឡើងលើសពី 15°C

b. ត្រូវផ្អាកការចៀរជ័រជាបណ្តោះអាសន្ន នៅពេលសីតុណ្ហភាពខ្យល់អាកាសជាមធ្យមឡើងលើសពី 40°C ក្នុងរយៈពេល5ថ្ងៃជាប់គ្នា និងស្រទាប់ស្លឹកខាងក្រោមប្រែទៅជាពណ៌លឿង ជ្រុះ (ផលប៉ះពាល់ពីភាពរាំងស្ងួតជីវសាស្ត្រចំពោះចំការកៅស៊ូនៅតំបន់ទួលភ្នំ) និងធ្វើការចៀរឡើងវិញនៅពេលសីតុណ្ហភាពធម្មតា។

c. ត្រូវផ្អាកការចៀរជ័រជាបណ្តោះអាសន្ន ក្នុងករណីអាកាសធាតុមិនអំណោយផល អាកាសធាតុអាក្រក់ខ្លាំងដែលប្រព្រឹត្តិទៅក្នុងរយៈពេលយូរ

d. មានតែចំឡើយ a និង ចំឡើយ b គឺត្រូវ

**សំណួរទី34 ៖ តើស្តង់ដារសម្រាប់ចង្អូរមុខចៀរត្រូវបានកំណត់ដូចម្តេច?**

a. ចង្អូរមុខចៀរត្រូវមានចំណោតត្រឹមត្រូវតាមការកំណត់ មានរាងផតស្នូកបាយជ្រូក កែងនឹងបន្ទាត់ព្រំខាងមុខ កែងនឹងបន្ទាត់ព្រំខាងក្រោយ មិនខុសចំណោតមុខចៀរ ចៀរមិនហួសបន្ទាត់ព្រំ និងមិនលោតរលក

b. ចង្អូរមុខចៀរត្រូវធានាថា មានជម្រៅ និងចំណាយអាចម៍ពន្លាកត្រឹមត្រូវតាមការកំណត់ ចង្អូរមុខចៀរមានរាងផតស្នូកបាយជ្រូក កែងនឹងបន្ទាត់ព្រំ មិនខុសចំណោតមុខចៀរ មិនលោតរលក និងចៀរដល់បន្ទាត់ព្រំ

c. ត្រឹមត្រូវតាមការគូសបែងចែកផ្ទាំងចៀរដំបូង នៅពេលបើកមុខចៀរ

d. មានតែចំឡើយ b និង ចំឡើយ c គឺត្រូវ

**សំណួរទី35 ៖ តើហេតុអ្វីមុខចៀរត្រូវកែងនឹងបន្ទាត់ព្រំខាងមុខ កែងនឹងបន្ទាត់ព្រំខាងក្រោយ?**

a. ដើម្បីកាត់អោយអស់សរសៃជ័រនៅតំបន់ទាញយកជ័រ និងប្រមូលជ័របានច្រើនបំផុត

b. ដើម្បីកាត់បន្ថយការស្ងួតផ្ទាំងចៀរលើដើមកៅស៊ូ

c. ដើម្បីរក្សាអោយផ្ទាំងចៀរស្អាត និង ជំរុញដល់ការបង្កើតសំបកថ្មីឡើងវិញ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី36 ៖ តើដើមបើកមុខចៀរជួសបន្ថែម ត្រូវរៀបចំបើកមុខចៀរនៅកំពស់ពីដីប៉ុន្មាន?**

a. បើកមុខចៀរនៅកំពស់ 1m ពីដី

b. បើកមុខចៀរនៅកំពស់ 1,2m ពីដី

c. បើកមុខចៀរនៅកំពស់ 1,3m ពីដី

d. បើកមុខចៀរនៅកំពស់ដូចគ្នានឹង មុខចៀររបស់ដើមកៅស៊ូកំពុងចៀរជ័រ ដែលបានបើកមុខចៀរមុន

**សំណួរទី37 ៖ តើចំពោះវិធីសាស្ត្រប្រមូលផលជាជ័រកក ការងារដែលត្រូវអនុវត្តមុន និង ក្រោយពេលធ្វើការចៀរជ័រលើដើមចៀរនីមួយៗ គឺមានអ្វីខ្លះ?**

a. មុនធ្វើការចៀរត្រូវបេកជ័រមុខដាក់ចូលក្នុងកន្ត្រកដាក់ជ័រផ្សេងៗ (ដែលស្ពាយតាមខ្លួន)

b. ចៀររួចនាំទឹកជ័រឲ្យហូរចូលក្នុងចាន ពិនិត្យគម្របចាន និងចានត្រងជ័រ ទើបដើរទៅចៀរនៅដើមផ្សេងទៀត

c. ទិសដើរទៅចៀរជ័រត្រូវធានាថា៖ ពេលដាក់ពន្លាកចៀរនៅចំណុចមុខចៀរនៃព្រំខាងក្រោយរបស់ដើមដែលរៀបចំចៀរនោះ ត្រូវមើលឃើញចំណុចមុខចៀរនៃព្រំខាងមុខរបស់ដើមក្នុងជួរដែលបានចៀរមុន។ ដល់វេនចៀរបន្ទាប់ត្រូវប្តូរទិសចាប់ផ្តើមធ្វើការចៀរ ឬ ប្តូរលំដាប់ដើមចៀរ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី38 ៖ តើចំពោះវិធីសាស្ត្រប្រមូលផលជាជ័រទឹក ការងារដែលត្រូវអនុវត្តមុន និង ក្រោយពេលធ្វើការចៀរជ័រលើដើមចៀរនីមួយៗ គឺមានអ្វីខ្លះ?**

a. មុនធ្វើការចៀរត្រូវបេកជ័រមុខ ជ័រចាន កែតម្រូវកងទ្រចាន និងស្លាបព្រាឡើងវិញ ជូតចានឲ្យស្អាត រួចដាក់ចានផ្កាប់លើកងទ្រចាន

b. ចៀររួចដាក់ចានឲ្យផ្ងារឡើងលើ និងនាំទឹកជ័រឲ្យហូរចូលក្នុងចាន ទើបដើរទៅចៀរដើមផ្សេងទៀត

c. ទិសដើរទៅចៀរជ័រត្រូវធានាថា៖ ពេលដាក់ពន្លាកចៀរនៅចំណុចមុខចៀរនៃព្រំខាងក្រោយរបស់ដើមដែលរៀបចំចៀរនោះ ត្រូវមើលឃើញចំណុចមុខចៀរនៃព្រំខាងមុខរបស់ដើមក្នុងជួរដែលបានចៀរមុន។ ដល់វេនចៀរបន្ទាប់ត្រូវប្តូរទិសចាប់ផ្តើមធ្វើការចៀរ ឬ ប្តូរលំដាប់ដើមចៀរ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី39 ៖ តើពេលធ្វើការចៀរនៅចំការប្រភេទ III (ចំការចៀរអស់ពីផលិតភាពហើយកាប់ដើមយកឈើ) ដែលត្រូវចៀរលើមែកខ្ពស់នៅខាងលើ ដើម្បីបង្ហូរទឹកជ័រឲ្យហូរចូលក្នុងចានគេត្រូវធ្វើដូចម្តេច?**

a. បង្ហូរទឹកជ័រពីស្លាបព្រាចុះមកចានត្រងទឹកជ័រ ដោយប្រើខ្សែនាំជ័រ

b. បង្ហូរទឹកជ័រពីស្លាបព្រាចុះមកចានត្រងទឹកជ័រ ដោយប្រើខ្សែនីឡុងសារជាតុ PP

c. បង្ហូរទឹកជ័រដោយធូតចង្អូរមួយវែងពីមុខចៀរចុះមកស្លាបព្រាហូរចូលក្នុងចាន

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី40 ៖ តើចំពោះចំការអាជីវកម្មដែលអនុវត្តវិធីសាស្ត្រប្រមូលផលជាជ័រទឹក ក្រោយពេលចៀរជ័ររួច ដល់ពេលណាកម្មករទើបអាចចាប់ផ្តើមធ្វើការសាជ័រ?**

a. នៅពេលណាក៏បាន អាស្រ័យទៅតាមសុខភាពរបស់កម្មករចៀរជ័រ

b. នៅពេលមានសញ្ញាបញ្ជាឲ្យធ្វើការសាជ័រពីប្រធានក្រុម/ប្រធានផ្នែក

c. នៅពេលមេឃរកភ្លៀង ឬ នៅពេលល្ងាចត្រជាក់

d. នៅពេលថ្ងៃត្រង់

**សំណួរទី41 ៖ តើដើម្បីធានាគុណភាពរបស់ជ័រវត្ថុធាតុដើម ការប្រគល់ និងទទួលជ័រទឹកគេត្រូវធ្វើដូចម្តេច?**

a. ពេលធ្វើការចាក់ជ័រទឹកពីប៉ោតសាជ័រ ចូលទៅប៉ោតដាក់ជ័រ គេត្រូវប្រើកន្ត្រងចម្រោះទឹកជ័រ ដោយមានទំហំរន្ធសំណាញ់ដូចបានកំណត់ និង ត្រូវគ្របប៉ោតឲ្យជិត ដើម្បីការពារកុំឲ្យវត្ថុផ្សេងៗ ស្លឹកឈើ ធ្លាក់ចូលក្នុងទឹកជ័រ

b. ពេលចាក់ជ័រទឹកពីប៉ោតដាក់ជ័រ ចូលទៅស៊ីទែនដាក់ជ័រនៅលើរថយន្តដឹកជ័រ គេត្រូវប្រើសំណាញ់ចម្រោះទឹកជ័រដោយមានទំហំរន្ធចំនួន 3mm និង ត្រូវកត់ត្រានូវតួលេខតាមដានទាំងបរិមាណ និង គុណភាពជ័ររបស់ពនចៀរនីមួយៗ និង ក្រុម/ផ្នែកកម្មករនីមួយៗ

c. ត្រូវរក្សាគុណភាពជ័រទឹក ដើម្បីធានាគុណភាពវត្ថុធាតុដើមនៃធាតុចូលសម្រាប់ផលិតកម្មកែច្នៃតាមតម្រូវការរបស់អង្គភាពនីមួយៗ ឬ កន្លែងប្រមូលទិញ។ ជាពិសេសកុំឲ្យមានលាយឡំនូវវត្ថុធាតុផ្សេងៗ (ដូចជាអាចម៍ពន្លាកចៀរ ស្លឹកឈើ មែកឈើ ដី ខ្សាច់ ធូលី ឬ កំទេចសំបកវេចខ្ចប់ និង ក្រណាត់ជូត...)

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី42 ៖ តើមូលហេតុអ្វីកម្មករត្រូវធ្វើការបែងចែកតាមប្រភេទជ័រនីមួយៗ នៅពេលប្រគល់ជ័រឲ្យទៅប្រធានក្រុម/ផ្នែកកម្មករ?**

a. <u>ដើម្បីរក្សាបាននូវគុណភាពនៃប្រភេទជ័រនីមួយៗ រួមចំណែកសម្រួលដល់ការបែងចែកវត្ថុធាតុដើមតាមប្រភេទនៃធាតុចូលសម្រាប់ផលិតកម្មកែច្នៃ និង ធានាដល់គុណភាពផលិតផលសំរេចក្រោយបានកែច្នៃ</u>

b. ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូនបានងាយស្រួល និង មានប្រសិទ្ធិភាពខ្ពស់

c. ដើម្បីសម្រួលដល់ការគណនាប្រាក់ឈ្នួលរបស់កម្មករ ដោយគិតតាមប្រភេទជ័រនីមួយៗ និង លើកកម្ពស់ការយល់ដឹងរបស់កម្មករ ក្នុងការថែរក្សាគុណភាពជ័រពីប្រភពជ័រវត្ថុធាតុដើម

d. មានតែចំឡើយ a និង ចំឡើយ c គឺត្រូវ

**សំណួរទី43 ៖ តើមូលហេតុអ្វីគេត្រូវប្រើកន្ត្រងច្រោះទឹកជ័រនៅពេលចាក់ជ័រពីប៉ោតចូលមកស៊ីទែនដាក់ជ័រ?**

a. <u>ដើម្បីយកចេញនូវវត្ថុធាតុផ្សេងៗ និង ធានាគុណភាពជ័រ</u>

b. ដើម្បីបង្កើនបរិមាណ DRC នៃជ័រទឹក

c. ដើម្បីកាត់បន្ថយករណីជ័រកក

d. ចំឡើយទាំង 3 ត្រូវទាំងអស់

**សំណួរទី44 ៖ តើតម្រូវការក្នុងការថែរក្សា និង ដឹកជញ្ជូនជ័រកកមានអ្វីខ្លះ?**

a. មិនត្រូវប្រើប្រាស់បាវ PP PVC សម្រាប់ដាក់ជ័រ ឬ ធ្វើជាគម្រប កម្រាលផ្ទៃបាតកន្លែងដាក់ជ័របានឡើយ

b. ត្រូវរៀបចំទុកដាក់ដោយបែងចែកឲ្យដាច់ដោយឡែកតាមប្រភេទជ័រនីមួយៗ ដើម្បីអាចមើលឃើញ និងសម្គាល់តាមប្រភេទជ័របានដោយងាយស្រួលនៅពេលធ្វើការប្រគល់ និង ទទួលជ័រ

c. ជ័រក្នុងស្តុកត្រូវរៀបចំទុកដាក់ ដោយបែងចែកតាមកាលបរិច្ឆេទដែលបានទទួលបញ្ចូលក្នុងស្តុក មិនត្រូវដាក់ឲ្យលាយឡំចូលគ្នាបានឡើយ

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី45 ៖ តើដើម្បីធានាគុណភាពជ័រ ពេលធ្វើការប្រគល់ និង ទទួលជ័រកកគេត្រូវធ្វើដូចម្ដេច?**

a. កម្មករនីមួយៗត្រូវធ្វើការប្រមូល បែងចែកជ័រតាមប្រភេទ និង ប្រមូលផ្ដុំមករោងប្រគល់ និងទទួលជ័រ

b. ធ្វើអនាម័យជ័រកកដែលប្រមូលបានពីចំការ យកចេញនូវវត្ថុធាតុផ្សេងៗដែលអាចមើលឃើញ ដូចជា៖ អាចម៍ពន្លាកចៀរ ស្លឹកឈើ សំបកឈើ សត្វល្អិត សរសៃបាវ PP PVC លោហធាតុ ដី ខ្សាច់ និង កំទេចកំទីផ្សេងៗ

c. គត់ត្រា និង រៀបចំទុកដាក់ឲ្យមានសណ្ដាប់ធ្នាប់ដោយបែងចែកតាមប្រភេទជ័រនីមួយៗ នៅរោងប្រគល់ និងទទួលជ័រសម្រាប់កម្មករនីមួយៗ

<u>d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី46 ៖ តើមូលហេតុអ្វី ពេលធ្វើការសាជ័រ (ប្រមូលជ័រទឹក) គេត្រូវប្រើប្រដាប់កៀរជ័រ?**

<u>a. ដើម្បីកៀរប្រមូលយកឲ្យអស់ជ័រក្នុងចាន</u>

b. ដើម្បីបង្កើនបរិមាណ DRC ក្នុងជ័រទឹក

c. ដើម្បីការពារកុំឲ្យជ័រឆាប់កកក្នុងចាន

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី47 ៖ តើតម្រូវការបច្ចេកទេសចំពោះពន្លាកចៀរ រួមមានអ្វី?**

a. ពន្លាកត្រូវសំលៀងឲ្យមុត ភ្លឺ ចៀរមុតស្រួល មានមុំផ្អៀងគ្រប់គ្រាន់ដែលអាចផ្ទឹបស្លាបពន្លាក (មុំពន្លាក) ស្មើល្មមនឹងមុខចៀរ ផ្នែកខាងក្រៅស្លាបពន្លាកត្រូវត្រង់ ផ្លែពន្លាកត្រង់ស្មើ មិនបាត់មុំពន្លាក

b. ពន្លាកចៀរធ្វើពីដែកថែបមានគុណភាពល្អ ត្រូវបានសំលៀងជាប្រចាំ និង អនាម័យស្អាត

c. តម្រូវឲ្យមាន "គម្របផ្លែពន្លាក" ឬ ប្រដាប់ការពារសុវត្ថិភាពសម្រាប់ផ្លែពន្លាក

<u>d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី48 ៖ តើតម្រូវការបច្ចេកទេសជាទូទៅ ចំពោះសម្ភារៈរបស់កម្មករទៅធ្វើការចៀរជ័រប្រចាំថ្ងៃ រួមមានអ្វី?**

a. ត្រូវសំអាតសម្ភារៈឲ្យស្អាត កុំឲ្យប៉ះពាល់ដល់គុណភាពជ័រ

b. កន្ត្រក ឬ ប៉ោតដាក់ជ័រត្រូវតែមាំល្អ ងាយស្រួលប្រើប្រាស់ និង ងាយស្រួលសំអាត

c. មិនត្រូវប្រើប្រាស់ក្រណាត់ជូតធ្វើអំពីសរសៃ PP ( *poly propylene* )

<u>d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី49 ៖ តើពេលដែលត្រូវធ្វើការបិទមុខចៀរ មុនឈប់សម្រាកក្នុងរដូវស្លឹកឈើជ្រុះ គឺនៅពេលណាខាងក្រោមនេះ?**

<u>a. ក្រោយពីបានប្រមែប្រមូលអស់ជ័រផ្សេងៗ ជ័រដី និង ធ្វើការសំអាតរានចៀរ</u>

b. ក្រោយវេនចៀរចុងក្រោយលើរានចៀរនីមួយៗ

c. ធ្វើស្របគ្នាក្នុងពេលតែមួយ តាមការបញ្ជារបស់ប្រធានក្រុម/ប្រធានផ្នែកកម្មករ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី50 ៖ តើបច្ចេកទេសបិទមុខចៀរមុនពេលឈប់សម្រាកក្នុងរដូវស្លឹកឈើជ្រុះ គេត្រូវអនុវត្តដូចម្តេច?**

a. លាប Vaselin ពីចំណុចបន្ទាត់ព្រំខាងក្រោយ ដល់ចំណុចបន្ទាត់ព្រំខាងមុខ លើសំបកដុះថ្មីឡើងវិញដែលជាប់នឹងមុខចៀរ មានផ្ទៃទទឹងចំនួន 5cm សម្រាប់សង្វាក់ចៀរ d3

b. លាប Vaselin ពីចំណុចបន្ទាត់ព្រំខាងក្រោយ ដល់ចំណុចបន្ទាត់ព្រំខាងមុខ លើសំបកដុះថ្មីឡើងវិញដែលជាប់នឹងមុខចៀរ មានផ្ទៃទទឹងចំនួន 4cm សម្រាប់សង្វាក់ចៀរ d4

c. លាប Vaselin ពីចំណុចបន្ទាត់ព្រំខាងក្រោយ ដល់ចំណុចបន្ទាត់ព្រំខាងមុខ លើសំបកដុះថ្មីឡើងវិញដែលជាប់នឹងមុខចៀរ មានផ្ទៃទទឹងចំនួន 3cm សម្រាប់សង្វាក់ចៀរ d2

d. មានតែចំឡើយ a និង ចំឡើយ b គឺត្រូវ

**សំណួរទី51 ៖ តើភារកិច្ចរបស់កម្មករមុននឹងឈប់សម្រាកចៀរជ័រលើចំការ ត្រូវធ្វើអ្វីខ្លះ?**

a. ធ្វើការចៀរជ័រយ៉ាងសកម្មដើម្បីទទួលបានទិន្នផល សម្រាប់ផែនការដែលនឹងទទួលនៅឆ្នាំក្រោយ

b. សម្អាតរានចៀររបស់ខ្លួន ប្រមែប្រមូលឲ្យអស់ជ័រផ្សេងៗ ជ័រដី។ ប្រមូលចាន កងទ្រចាន ស្លាបព្រា សម្អាតឲ្យស្អាត រួចរក្សាទុកនៅកន្លែងជានាសុវត្ថិភាព។ បោសសម្អាត ប្រមូលស្លឹកឈើ ធ្វើផ្លូវការពារភ្លើង ឆេះចំការ

c. ប្រមែប្រមូលឲ្យអស់ជ័រផ្សេងៗ ជ័រដី ការពារភ្លើងឆេះចំការក្នុងរដូវប្រាំង

d. ប្រគល់រានចៀរទៅឲ្យបុគ្គលិកសន្តិសុខការពារចំការដើម្បីឈប់សម្រាក់ចៀរ

**សំណួរទី52 ៖ ការបែងចែករានចៀរត្រូវបានកំណត់ចំពោះ ចំការអាជីវកម្មប្រភេទ I ពីឆ្នាំទី2 ដែលអនុវត្តវិធីសាស្ត្រប្រមូលផលជាជ័រទឹក គឺ៖**

a. នៅតំបន់ដីរាបស្មើ ចំនួន 600 – 650 ដើមចៀរ / រានចៀរ

b. នៅតំបន់ដីរាបស្មើ ចំនួន 700 – 750 ដើមចៀរ / រានចៀរ

c. នៅតំបន់ដីជម្រាល >15° ឬ ដង់ស៊ីតេរង្វើល ចំនួន 500 – 550 ដើមចៀរ / រានចៀរ

d. មានតែចំឡើយ a និង ចំឡើយ c គឺត្រូវ

**សំណួរទី53 ៖ ការបែងចែករានចៀរត្រូវបានកំណត់ចំពោះ ចំការអាជីវកម្មប្រភេទ I ពីឆ្នាំទី2 ដែលអនុវត្តវិធីសាស្ត្រប្រមូលផលជាជ័រកក គឺ៖**

a. នៅតំបន់ដីរាបស្មើ ចំនួន 600 – 650 ដើមចៀរ / រានចៀរ

b. នៅតំបន់ដីរាបស្មើ ចំនួន 700 – 750 ដើមចៀរ / រានចៀរ

c. នៅតំបន់ដីជម្រាល >15° ឬ ដង់ស៊ីតេរង្វើល ចំនួន 600 – 650 ដើមចៀរ / រានចៀរ

d. មានតែចំឡើយ b និង ចំឡើយ c គឺត្រូវ

**សំណួរទី54 ៖ ការបែងចែកកានចៀវត្រូវបានកំណត់ចំពោះ ចំការអាជីវកម្មប្រភេទ III ដែលអនុវត្តវិធីសាស្ត្រប្រមូលផលជាជ័រទឹក គឺ៖**

a. នៅតំបន់ដីរាបស្មើ ចំនួន 250 – 300 ដើមចៀរ / កានចៀរ

b. នៅតំបន់ដីរាបស្មើ ចំនួន 300 – 350 ដើមចៀរ / កានចៀរ

c. នៅតំបន់ដីជម្រាល >15° ឬ ដង់ស៊ីតេរង្វើល ចំនួន 220 – 250 ដើមចៀរ / កានចៀរ

d. មានតែចំលើយ a និង ចំលើយ c គឺត្រូវ

**សំណួរទី55 ៖ តើបច្ចេកទេសលាបថ្នាំរំញោចលើសំបកដុះថ្មីឡើងវិញ *(Pa: Panel application)* ត្រូវបានអនុវត្តដូចម្តេច?**

a. ប្រើជក់លាបថ្នាំលេខ 8 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 0,8cm លាបថ្នាំឲ្យស្តើងស្មើលើសំបកដុះថ្មីឡើងវិញ មានផ្ទៃទទឹងចំនួន 1cm ដែលជាប់នឹងមុខចៀរ

b. ប្រើជក់លាបថ្នាំលេខ 10 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 1cm លាបថ្នាំឲ្យស្តើងស្មើលើសំបកដុះថ្មីឡើងវិញ មានផ្ទៃទទឹងចំនួន 1cm ដែលជាប់នឹងមុខចៀរ

c. ប្រើជក់លាបថ្នាំលេខ 8 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 0,8cm លាបថ្នាំមួយស្រទាប់ឲ្យស្តើងស្មើចំពីលើមុខចៀរ

d. ប្រើជក់លាបថ្នាំលេខ 10 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 1cm លាបថ្នាំមួយស្រទាប់ឲ្យស្តើងស្មើចំពីលើមុខចៀរ

**សំណួរទី56 ៖ តើបច្ចេកទេសប្រើប្រាស់ថ្នាំរំញោចលើមុខចៀរ ដោយមិនបកជ័រមុខ *(La: Lace application)* ត្រូវបានអនុវត្តដូចម្តេច?**

a. ប្រើជក់លាបថ្នាំលេខ 8 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 0,8cm លាបថ្នាំឲ្យស្តើងស្មើលើសំបកដុះថ្មីឡើងវិញ មានផ្ទៃទទឹងចំនួន 1cm ដែលជាប់នឹងមុខចៀរ

b. ប្រើជក់លាបថ្នាំលេខ 10 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 1cm លាបថ្នាំឲ្យស្តើងស្មើលើសំបកដុះថ្មីឡើងវិញ មានផ្ទៃទទឹងចំនួន 1cm ដែលជាប់នឹងមុខចៀរ

c. ប្រើជក់លាបថ្នាំលេខ 8 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 0,8cm លាបថ្នាំមួយស្រទាប់ឲ្យស្តើងស្មើចំពីលើមុខចៀរ

d. ប្រើជក់លាបថ្នាំលេខ 10 ឬ ប្រាសកែច្នៃមានទំហំទទឹងចំនួន 1cm លាបថ្នាំមួយស្រទាប់ឲ្យស្តើងស្មើចំពីលើមុខចៀរ

**សំណួរទី57 ៖ តើតម្រូវការចំពោះកំរិតជំនាញវិជ្ជាជីវៈ របស់កម្មករចៀរជ័រមានដូចម្តេច?**

a. ត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមួយ(ទ្រឹស្តី និងអនុវត្តជាក់ស្តែង) និងទទួលបានលទ្ធផលឆ្លើយតបតាមតម្រូវការ ទទួលបានលិខិតបញ្ជាក់ការសិក្សាជាប់និទ្ទេសចាប់ពីល្អបង្គួរឡើង

b. កម្មករមានកំរិតវប្បធម៌ថ្នាក់ទី12 ជាប់និទ្ទេសចាប់ពីមធ្យមឡើង

c. កម្មករដែលមានអ្នកផ្ទះជាកម្មករមានអតីតភាពការងារចៀរជ័រយូរឆ្នាំមកហើយ

d. មានតែចំឡើយ a និង ចំឡើយ b គឺត្រូវ

**សំណួរទី58 ៖ តើផលប្រយោជន៍នៃការធ្វើវ៉ាក់សាំង ដើម្បីបង្កើនទិន្នផលជ័រទឹក បានបង្ហាញច្បាស់បំផុតតាមរយៈលទ្ធផលមួយណាខាងក្រោមនេះ?**

a. <u>ពន្យារពេលហូរជ័រ</u>

b. បង្កើនផលិតភាពចៀរជ័រ

c. បន្ថយអត្រាកើតមានជម្ងឺស្ងួតផ្ទាំងចៀរ

d. សន្សំសំចៃបរិមាណជីកសិកម្ម

**សំណួរទី59 ៖ តើដើម្បីអោយដើមកៅស៊ូមានប្រតិកម្មវិជ្ជមានជាមួយនឹងថ្នាំរំញោច និងអោយទិន្នផលជ័រខ្ពស់បំផុត គួរតែលាបថ្នាំរំញោចមុនពេលធ្វើការចៀរលើកបន្ទាប់ប៉ុន្មានម៉ោង?**

a. ពី12 ដល់ 24ម៉ោង

b. <u>ពី24 ដល់ 48ម៉ោង</u>

c. ពី48 ដល់ 72ម៉ោង

d. ពី72 ដល់ 96ម៉ោង

**សំណួរទី60 ៖ តើចំនួនដងប្រើប្រាស់ថ្នាំរំញោច(សង្វាក់ធ្វើរំញោច) អាស្រ័យទៅតាមកត្តាណាខាងក្រោមនេះ?**

a. អាស្រ័យទៅតាមលទ្ធផលឆ្លើយតបពីការធ្វើរំញោចនៃប្រភេទពូជក្លូន

b. អាស្រ័យទៅតាមតាមសង្វាក់ចៀរ

c. អាស្រ័យទៅតាមអាយុចៀរ

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី61 ៖ ចូរជ្រើសរើសវិធីសាស្ត្រលាបថ្នាំរំញោចណាមួយខាងក្រោមនេះ ជាជម្រើសដ៏ត្រឹមត្រូវបំផុត ដែលត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់មុខចៀរផ្ងារ**

a. <u>Pa ៖ លាបថ្នាំរំញោចលើសំបកដុះថ្មីឡើងវិញ ដែលកៀកជិតនឹងមុខចៀរ</u>

b. La ៖ លាបថ្នាំរំញោចលើមុខចៀរ ដោយមិនបកជ័រមុខ

c. Ba ៖ លាបថ្នាំរំញោចលើសំបក ដែលបានកោសសំអាតស្រទាប់ខាងក្រៅ

d. Ga ៖ លាបថ្នាំរំញោចលើមុខចៀរ ក្រោយពីបានបកជ័រមុខ

**សំណួរទី62 ៖ ចូរជ្រើសរើសវិធីសាស្ត្រលាបថ្នាំរំញោចណាមួយខាងក្រោមនេះ ជាជម្រើសដ៏ត្រឹមត្រូវបំផុត ដែលត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់មុខចៀរផ្កាប់**

a. Pa ៖ លាបថ្នាំរំញោចលើសំបកដុះថ្មីឡើងវិញ ដែលកៀកជិតនឹងមុខចៀរ

b. <u>La ៖ លាបថ្នាំរំញោចលើមុខចៀរ ដោយមិនបកជ័រមុខ</u>

c. Ba ៖ លាបថ្នាំរំញោចលើសំបក ដែលបានកោសសំអាតស្រទាប់ខាងក្រៅ

d. Ga ៖ លាបថ្នាំរំញោចលើមុខចៀរ ក្រោយពីបានបកជ័រមុខ

**សំណួរទី63 ៖ តើស្តង់ដារបច្ចេកទេសនៃចំការដែលមិនអនុញ្ញាតឲ្យប្រើប្រាស់ថ្នាំរំញោច មានដូចម្តេច?**

a. បរិមាណជ័រស្ងួត (DRC) របស់ចំការទាបជាង 25%

b. អត្រាដើមស្ងួតផ្ទាំងចៀរទាំងមូលខ្ពស់ជាងអត្រាដែលទទួលបានពីការធ្វើសារពើភ័ណ្ឌចំការលើកមុន ក្នុងកំរិតខ្ពស់ជាង 3% ចំពោះចំការអាជីវកម្មប្រភេទ I (ចៀរផ្ទារលើសំបកកំណើតតែប៉ុណ្ណោះ)

c. អត្រាដើមត្រូវស្ងួតផ្ទាំងចៀរទាំងមូលខ្ពស់ជាងអត្រាដែលទទួលបានពីការធ្វើសារពើភ័ណ្ឌចំការលើកមុន ក្នុងកំរិតខ្ពស់ជាង 10% ចំពោះចំការអាជីវកម្មប្រភេទ II (ចៀរផ្អាប់ដោយមានការត្រួតពិនិត្យ)

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី64 ៖ តើវិធីសាស្ត្រប្រើប្រាស់ថ្នាំរំញោចទាំងឡាយណា ដែលកំពុងអនុវត្តដើម្បីបង្កើនទិន្នផលជ័រ ក្នុងពេលបច្ចុប្បន្ន?**

a. ប្រើប្រាស់សមាសធាតុគីមីមានធាតុសកម្ម *ethephon* លាបលើដើមកៅស៊ូ

b. ឲ្យដើមកៅស៊ូស្រូបយកឧស្ម័ន *ethylene* ដោយផ្ទាល់

c. ប្រើកាំរស្មី laser ដើម្បីធ្វើរំញោចលើដើមកៅស៊ូ

d. មានតែចំឡើយ a និង ចំឡើយ b គឺត្រូវ

**សំណួរទី65 ៖ តើធាតុសកម្ម *ethephon* មានប៉ះពាល់អ្វីដល់គុណភាពឈើកៅស៊ូឬទេ?**

a. កំពុងស្រាវជ្រាវ មិនទាន់មានការណែនាំដល់ផលិតកម្មឈើកៅស៊ូនៅឡើយ

b. មានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គុណភាពឈើ លើបញ្ហាពណ៌

c. គុណភាពឈើធ្លាក់ចុះ ក្រោយបានប្រើប្រាស់ជាបន្តបន្ទាប់ក្នុងរយៈពេលវែងតែប៉ុណ្ណោះ

d. គ្មានប៉ះពាល់អ្វីដល់គុណភាពឈើកៅស៊ូទេ

**សំណួរទី66 ៖ តើតម្រូវការចំពោះសុវត្ថិភាពការងារនៅពេលប្រើប្រាស់ថ្នាំរំញោចនៅចំការ មានដូចម្តេច?**

a. ចៀសវាងកុំអោយថ្នាំរំញោចប៉ះពាល់ដល់ស្បែក និង ភ្នែក

b. ពេលលាបថ្នាំរំញោចលើមុខចៀរផ្អាប់ ត្រូវពាក់វែនតាការពារ

c. មិនត្រូវពិសាចំណីអាហារ ផឹកទឹក ឬ ជក់បារី ក្នុងពេលកំពុងធ្វើការលាបថ្នាំរំញោចជាដាច់ខាត

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី67 ៖ ចូររៀបរាប់អំពីរបៀបសង្គ្រោះបឋម ក្នុងករណីថ្នាំរំញោចប៉ះពាល់ដល់ស្បែក និង ខ្ទាតចូលភ្នែក ក្នុងពេលកំពុងធ្វើការលាបថ្នាំរំញោចនៅចំការ**

a. ករណីថ្នាំរំញោចប៉ះពាល់ដល់ស្បែក ត្រូវលាងនឹងសាប៊ូ និង ទឹកក្តៅអ៊ុនៗភ្លាម

b. ករណីថ្នាំរំញោចប៉ះពាល់ដល់ភ្នែក ត្រូវលាងភ្នែកភ្លាម លាងឲ្យបានច្រើនដងនឹងទឹកស្អាត

c. ត្រូវបញ្ជូនអ្នកជម្ងឺដល់គ្រឹះស្ថានសុខាភិបាលដែលនៅជិតជាងគេដើម្បីសង្គ្រោះបឋម ក្នុងករណីមានរោគសញ្ញាប្រតិកម្មនឹងថ្នាំ ឬ អាចបង្កប្រួសធ្ងន់ដល់ភ្នែក ឬ ផ្នែកស្បែកដែលប៉ះពាល់នឹងថ្នាំ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី68 ៖ តើការរក្សាទុកថ្នាំរំញោចដែលមិនទាន់ប្រើប្រាស់ ត្រូវធ្វើដូចម្តេច?**

a. ត្រូវរក្សាទុកក្នុងម្លប់ ជៀសវាងត្រូវពន្លឺព្រះអាទិត្យដោយផ្ទាល់ ការប្រើប្រាស់ត្រូវគោរពតាមកាលកំណត់ដែលមានបញ្ជាក់លើសំបកវេចខ្ចប់

b. រក្សាទុកនៅកន្លែងដាច់ដោយឡែក មានទ្វារបិទជិត ជានាសុវត្ថិភាព និងសីតុណ្ហភាពពី 20 - 30$^{0}$C

c. រក្សាទុកនៅកន្លែងដែលកូនក្មេងមិនអាចប៉ះពាល់បាន

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី69 ៖ តើករណីរកឃើញមានដើមស្ងួតផ្ទាំងចៀរ កម្មករចៀរជ័រនឹងដោះស្រាយដូចម្តេច?**

a. គូសចំណាំ រួចរាយការណ៍ដល់ប្រធានក្រុម/ផ្នែកកម្មករ បុគ្គលិកបច្ចេកទេស ដើម្បីមានវិធានការដោះស្រាយ

b. ត្រូវឈប់ចៀរ និង ពិនិត្យតំបន់ស្ងួតជ័រ ដើម្បីអនុវត្តការចៀរដាច់ដោយឡែក ឬ ប្តូរផ្ទាំងចៀរ

c. លាបថ្នាំរំញោច និង ដាក់ជីបន្ថែម រួចបន្តធ្វើការចៀរ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី70 ៖ តើជម្ងឺណាមានប្រភពបង្កជម្ងឺ ដូចគ្នានឹងជម្ងឺជ្រុះស្លឹករដូវភ្លៀង?**

a. ជម្ងឺឆេះរួញកន្ទុយស្លឹក

b. ជម្ងឺប្រផេះស

c. ជម្ងឺផ្កាកុឡាប

d. ជម្ងឺឆ្នូតខ្មៅ

**សំណួរទី71 ៖ តើតម្រូវការ "ត្រូវទាំង 4" នៅពេលប្រើប្រាស់ថ្នាំការពាររុក្ខជាតិឲ្យមានប្រសិទ្ធិភាពខ្ពស់ គឺជាអ្វី?**

a. ត្រូវថ្នាំ ត្រូវពេល ត្រូវរបៀប ត្រូវកំហាប់ និង បរិមាណ

b. ត្រូវថ្នាំ ត្រូវបរិមាណ ត្រូវតំលៃ ត្រូវតាមការកំណត់

c. ត្រូវមុខសញ្ញា ត្រូវរបៀប ត្រូវកន្លែង ត្រូវបរិមាណ និង កំហាប់

d. ត្រូវប្រភេទថ្នាំ ត្រូវកាលកំណត់ ត្រូវរបៀប ត្រូវបរិមាណ

**សំណួរទី72 ៖ តើដើម្បីជានាសុវត្ថិភាព នៅពេលធ្វើការបាញ់ថ្នាំការពាររុក្ខជាតិត្រូវធ្វើអ្វី?**

a. មានបំពាក់សម្ភារៈការពារសុវត្ថិភាពការងារ មិនទទួលទានចំណីអាហារ ជាពិសេសមិនពិសារបារី ក្នុងពេលកំពុងបាញ់ថ្នាំ

b. ពិនិត្យធុងបាញ់ថ្នាំ ដើម្បីជានាថាមិនលេចធ្លាយនៅពេលមានសម្ពាធខ្យល់

c. មិនត្រូវបាញ់បញ្ច្រាស់ទិសខ្យល់បក់ និងចៀសវាងកុំឲ្យថ្នាំប៉ះពាល់ដល់សរពាង្គកាយ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី73 ៖ តើលើសំបកវេចខ្ចប់ថ្នាំការពាររុក្ខជាតិ មានខ្សែបន្ទាត់ពណ៌ក្រហម និង សញ្ញាមួយចំនួនទៀត គឺចង់បញ្ជាក់ពីភាពពុលរបស់ថ្នាំដល់កំរិតណា?**

a. ពុលយ៉ាងខ្លាំង និង ពុលកំរិតខ្ពស់

b. ពុលកំរិតមធ្យម

c. ពុលកំរិតស្រាល

d. ពុលតិចតួច

**សំណួរទី74 ៖ តើសមាសធាតុណាក្នុងថ្នាំការពាររុក្ខជាតិ មានប្រសិទ្ធិភាពខ្ពស់បំផុតចំពោះមុខសញ្ញាបង្ការ និងព្យាបាលជម្ងឺ?**

a. ធាតុសកម្ម

b. សមាសធាតុបន្ទាប់បន្សំ

c. សារធាតុរំលាយ

d. ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់

**សំណួរទី75 ៖ តើជម្ងឺបូទ្រីយ៉ូឌីផ្លូឌីយ៉ា (*Botryodiplodia*) បំផ្លាញខ្លាំងដល់ផ្នែកណារបស់ដើមកៅស៊ូចៀរជ័រ?**

a. ប្រព័ន្ធបំពង់ជ័រក្នុងតួដើម ពីគល់ដល់កន្លែងបែកមែក (ចំពាម)

b. តួដើម និង មែក មានសំបកឈានទៅពណ៌ត្នោត

c. ផ្ទាំងចៀរ

d. ឫស

**សំណួរទី76 ៖ តើការបាញ់ថ្នាំព្យាបាលជម្ងឺបូទ្រីយ៉ូឌីផ្លូឌីយ៉ា (*Botryodiplodia*) គេត្រូវអនុវត្តនៅរដូវណាក្នុងឆ្នាំដើម្បីទទួលបាននូវប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់បំផុត?**

a. ដើមរដូវភ្លៀង

b. រដូវប្រាំង

c. រដូវកៅស៊ូលាស់ស្លឹកថ្មី

d. ពេញមួយឆ្នាំ

**សំណួរទី77 ៖ តើពេលធ្វើការបាញ់ថ្នាំបង្ការជម្ងឺប្រផេះសនៅចំការអាជីវកម្ម គេត្រូវបាញ់ទៅលើផ្នែកណារបស់ដើមកៅស៊ូ ដើម្បីឲ្យមានប្រសិទ្ធិភាពខ្ពស់?**

a. ស្លឹកទាំងអស់

b. ស្រទាប់ស្លឹកចាស់

c. តួដើម

d. ជុំវិញគល់

**សំណួរទី78 ៖ តើផ្នែកសំខាន់របស់ដើមកៅស៊ូដែលផ្សិតកូរីនែសប៉ូរ៉ា (*Corynespora*) បង្កការខូចខាតនោះ គឺជាផ្នែកណា?**

a. ស្លឹក

b. ទងស្លឹក

c. ខ្នែង

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

**សំណួរទី79 ៖ តើជម្ងឺកូរីនែសប៉ូរ៉ា (*Corynespora*) តែងតែកើតមាន និង បំផ្លាញនៅរដូវណា?**

a. រដូវភ្លៀង

b. រដូវប្រាំង

c. រដូវដើមកៅស៊ូលាស់ស្លឹកថ្មី

d. <u>ពេញមួយឆ្នាំ</u>

**សំណួរទី80 ៖ តើជម្ងឺណាខាងក្រោមនេះ បង្កផលប៉ះពាល់ដល់ផ្ទាំងចៀរដោយផ្ទាល់?**

a. ជម្ងឺឆ្នូតខ្មៅ

b. ជម្ងឺស្ងួតផ្ទាំងចៀរ

c. ជម្ងឺប្រេះសំបកគល់ដើម និង ស្ងួតមុខចៀរ

d. <u>ចំឡើយទាំង 3 ខាងលើត្រូវទាំងអស់</u>

-ចប់-